# តើយើងអាចត្រៀមខ្លួនយើងសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ថ្នាក់សិក្ខាសាលា

ប៉ុលបានបញ្ជូនសំបុត្រទីមួយរបស់លោកទៅកាន់ពួកថែស្សាឡូនីច ដោយការចែកចាយការទូន្មានអំពីរបៀប ដែលពួកបរិសុទ្ធអាចត្រៀមខ្លួនបានកាន់តែល្អ ដើម្បីជួបព្រះអង្គសង្គ្រោះនៅពេលការយាងមកជាលើកទីពីររបស់ទ្រង់ ។

សូមអាន ថែស្សាឡូនីច ទី១ ៥:១៤–២២ ហើយមើលថា អ្នកទទួលបានការយល់ដឹងអ្វីខ្លះអំពីការត្រៀមខ្លួន ។ សូមបើកចិត្តឲ្យទូលាយចំពោះគំនិតអំពីការបង្រៀនណាមួយដែលអាចមានប្រយោជន៍ជាពិសេសសម្រាប់អ្នក ។

- តើការបង្រៀនទាំងនេះមួយណាដែលមានអត្ថន័យបំផុតចំពោះអ្នក ? ហេតុអ្វី ?

សូមស្វែងរកខគម្ពីរមួយ ឬពីរដែលជួយបង្កើនការយល់ដឹងរបស់អ្នកអំពីការបង្រៀនដែលអ្នកបានជ្រើសរើស ។ ( អ្នកអាចនឹងប្រើសេចក្ដីយោងឆ្លងឬរកមើលប្រធានបទនៅក្នុងសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ) ។

- តើព្រះយេស៊ូវគ្រីស្ទបានជួយអ្នកដោយរបៀបណា ឬតើទ្រង់នឹងជួយអ្នកដោយរបៀបណា ដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ? តើអ្នកអាចរៀនអ្វីខ្លះអំពីទ្រង់មកពីការណ៍នេះ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *How Can We Prepare Ourselves for the Second Coming of Jesus Christ ?*
Cambodian. PD60012661 258. Printed in the United States of America.